**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ អង្គារ ៥ រោច ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសេចក្តីព្រាងគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០១៩-២០២៨ និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៤ មាត្រា ៨ និងមាត្រា ១០ នៃអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម

នាព្រឹកថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាអំពី ***"សេចក្តី-ព្រាងគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០១៩-២០២៨ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៤ មាត្រា ៨ និងមាត្រា ១០ នៃអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម"*** ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

ស្របជាមួយនឹងដំណើរឆ្ពោះទៅមុខនៃកិច្ចអភិវឌ្ឍ ការធ្វើទំនើបកម្ម និងនិរន្តរភាពទីក្រុង ក៏ដូចជា ការបន្ស៊ាំខ្លួនទៅនឹងបរិបទសកលនៃការរស់នៅប្រកបដោយចីរភាព, ការមានជីវភាពកាន់តែប្រសើរឡើងរបស់ប្រជាពលរដ្ឋកម្ពុជា តម្រូវការមូលដ្ឋានចម្បងរបស់ពួកគាត់ គឺការផ្លាស់ប្តូរទម្លាប់នៃការរស់នៅដែលមានផាសុកភាព និងសុខមាលភាពសាធារណៈ ។ ជាកិច្ចឆ្លើយតបទៅនឹងតម្រូវជាក់ស្តែងរបស់ប្រជាពលរដ្ឋ, ការគាំពារនូវគុណភាពទឹក ដី ខ្យល់ ពីការបំពុល គឺត្រូវដើរទន្ទឹមគ្នានឹងកិច្ចអភិវឌ្ឍនានា ដែលក្នុងនោះ ការទប់ស្កាត់ការបំពុលពីសំរាម សំណល់រឹងទីប្រជុំជន ជាកិច្ចការចម្បងមួយក្នុងកិច្ចការចម្បងធំៗដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងយកចិត្តទុកដាក់ និងដោះស្រាយជាបន្ទាន់ និងជានិរន្ត ។ ការពង្រឹងកិច្ចការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គឺត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់ ចាប់តាំងពីចំណុចបង្កើតសំរាម សំណល់រឹង រហូតដល់ការការច្នៃ និងទុកដាក់ចុងក្រោយនៃសំរាម សំណល់រឹងទាំងនេះ ដោយត្រូវស្ថិតនៅក្រោមក្របខណ្ឌគោលនយោបាយ ផែនការសកម្មភាព និងវិធានការអនុវត្តន៍ជាក់លាក់ច្បាស់លាស់ និងម៉ឺងមាត់ ។

ក្នុងន័យនេះ, ការដាក់ចេញនូវគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នេះគឺជាកិច្ចការបន្ទាន់ និងប្រកបដោយសារវន្ត ក្នុងការដោះស្រាយនូវបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត ដើម្បីលើកកម្ពស់សុខភាពសាធារណៈ សោភ័ណភាពទីប្រជុំជន និងការពារប្រព័ន្ធអេកូឡូស៊ី ដែលជាឧត្តមប្រយោជន៍ជាតិ ។ ការរៀបចំ *"សេចក្តីព្រាងគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០១៩-២០២៨"* មានគោលបំណងដើម្បីពង្រឹង និងដោះស្រាយបញ្ហាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីប្រែក្លាយប្រទេសកម្ពុជាឱ្យមានសោភ័ណភាព បរិស្ថានស្អាត និងអនាម័យល្អ ប្រកបដោយភាពទាក់ទាញ ។ *"សេចក្តីព្រាងគោលនយោបាយ"* នេះ នឹងត្រូវបានគាំទ្រ និងអនុវត្តតាមការកំណត់ក្របខណ្ឌយុទ្ធសាស្ត្រគន្លឹះសំខាន់ៗ ដូចខាងក្រោម ÷

- កំណត់ក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត ក្របខណ្ឌការងារ និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,
- រៀបចំឱ្យមានយន្តការ និងវិធានការ បច្ចេកទេស បច្ចេកវិទ្យា និងធនធាន សម្រាប់ការគ្រប់គ្រង និងគាំទ្រលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,
- ជំរុញ និងលើកទឹកចិត្តការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន របស់រដ្ឋបាលថ្នាក់ក្រោមជាតិ,
- បង្កើតឱកាសវិនិយោគដល់វិស័យឯកជន លើការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,
- លើកកម្ពស់ការចូលរួម គាំទ្រ ពីសាធារណជន វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងការអនុវត្តកាតព្វកិច្ចគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយសុវត្ថិភាពបរិស្ថាន និង
- លើកកម្ពស់ការអប់រំ ផ្សព្វផ្សាយ និងជំរុញឱ្យមានការចូលរួមពីសាធារណជន ។

ចំណែកឯសេចក្តីព្រាងអនុក្រឹត្យស្តីពី *"ការកែសម្រួលមាត្រា ៤ មាត្រា ៨ និងមាត្រា ១០ នៃអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម"* មានគោលបំណងកែសម្រួល និងធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់មូលនិធិបរិស្ថាន និងសង្គម តាមរយៈការកំណត់ប្រភពចំណូល និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម ឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដែលក្នុងនោះ រួមមាន ÷(១.) សមាសភាពរបស់គណៈកម្មាធិការមូលនិធិ បរិស្ថាន និងសង្គម(២.) ប្រភពចំណូលរបស់មូលនិធិបរិស្ថាន និងសង្គម និង (៣.) សកម្មភាពដែលអនុញ្ញាតឱ្យប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ក្រុមការងារនៃក្រសួងបរិស្ថាន ដែលបានរៀបចំសេចក្តីព្រាងទាំងពីរដ៏មានសារៈសំខាន់នេះ និងថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា និងបានផ្តល់ជាធាតុចូល សម្រាប់កែលម្អបន្ថែមលើសេចក្តីព្រាងទាំងពីរនេះ ។